**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ...ធ៥-០២៤-២៩៤ ស.ន.ក

*ថ្ងៃចន្ទ ៥រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤*

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី១៧៤

ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ឱ្យបានជ្រាបថា ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី១៧៤ ដែលមានឥណប្រតិទាន ៩១ថ្ងៃ ១៨២ថ្ងៃ និង៣៦៤ថ្ងៃ នឹងត្រូវដាក់ឱ្យដេញថ្លៃនៅថ្ងៃអង្គារ ៦រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤ និងឥណប្រតិទាន ៧ថ្ងៃនឹងត្រូវដាក់ឱ្យដេញថ្លៃនៅថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤។ ការទូទាត់សម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាព ដោយមានការធានា (LPCO) លើកទី១៧៤ គ្រប់ឥណប្រតិទាន នឹងត្រូវធ្វើឡើងនៅថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤។ព័ត៌មានពាក់ព័ន្ធនឹងការដេញថ្លៃនេះមានដូចតទៅ៖

- -ពេលវេលាដាក់ដេញថ្លៃ : ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ ១១:០០ ព្រឹក
- -នីតិវិធីដេញថ្លៃ : ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល) និងអត្រាការប្រាក់ដាក់ដេញថ្លៃជាភាគរយ (ពីរខ្ទង់ក្រោយក្បៀស)
- -វត្ថុធានា : NCD ឬ មូលបត្ររដ្ឋ ជាវត្ថុធានាត្រូវមានឥណប្រតិទានធំជាង ឬ ស្មើនឹងឥណប្រតិទានរបស់ LPCO
- -ទំហំទឹកប្រាក់ដេញថ្លៃអប្បបរមា : ២០០.០០០.០០០ (ពីររយលាន) រៀល
- -ទំហំទឹកប្រាក់ដេញថ្លៃអតិបរមា : មិនកំណត់

ទំហំទឹកប្រាក់ដាក់ឱ្យដេញថ្លៃ អត្រាការប្រាក់ Haircut លើវត្ថុធានា និងថ្ងៃឥណប្រតិទាន មានដូចតទៅ៖

| ប្រភេទ LPCO | ថ្ងៃឥណប្រតិទាន | ទឹកប្រាក់ដាក់ឱ្យដេញថ្លៃ | អត្រាការប្រាក់ដាក់ដេញថ្លៃអប្បបរមា | Haircut លើ USD-NCD |
|---|---|---|---|---|
| ៧ថ្ងៃ(D07) | ៦ មិថុនា ២០២៤ | ៧០.០០០.០០០.០០០ រៀល | ៣,៧៥% | ៣% |
| ៩១ថ្ងៃ (D91) | ២៩ សីហា ២០២៤ | ៤០.០០០.០០០.០០០ រៀល | ៤,០០% | ៣% |
| ១៨២ថ្ងៃ (D182) | ២៨ វិច្ឆិកា ២០២៤ | ២៥.០០០.០០០.០០០ រៀល | ៤,២៥% | ៣% |
| ៣៦៤ថ្ងៃ (D364) | ២៩ ឧសភា ២០២៥ | ៥.០០០.០០០.០០០ រៀល | ៤,៥០% | ៣% |



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ការដេញថ្លៃត្រូវធ្វើតាមផ្លែតហ្វមធនាគារជាតិនៃកម្ពុជា (NBCP)។ ក្នុងករណី NBCP មិនអាចអនុវត្តបាន ពាក្យសុំដេញថ្លៃត្រូវបញ្ជូនតាមសារអេឡិចត្រូនិក Bod.lpco@nbc.gov.kh ឬដាក់ក្នុងស្រោមសំបុត្របិទជិត និងផ្ញើមកនាយកដ្ឋានទីផ្សាររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជា ឱ្យបានមុនម៉ោង ១១:០០ ព្រឹក នាថ្ងៃដដែល។

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសនៅម៉ោង ២:០០ រសៀល នាថ្ងៃដដែល។ គ្រឹះស្ថានដែលដេញថ្លៃឈ្នះត្រូវអនុវត្តតាមសេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO។

គណៈកម្មាធិការដេញថ្លៃរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការដេញថ្លៃប្រតិបត្តិការ LPCO។

**សូមទំនាក់ទំនង ៖**


លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣<br>
(៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨)

សារអេឡិចត្រូនិក : lpco.info@nbc.gov.kh


**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**

www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA